ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

រវាង

## មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

និង

## អង្គការសេវាសង្គមសុខភាពបុរស

## ក្នុងការបង្ការមេរោគអេដស៍/ជំងឺអេដស៍ និង កាត់បន្ថយផលប៉ះពាល់ នៃការប្រើប្រាស់គ្រឿងញៀន

ចាប់ពីខែ សីហា ឆ្នាំ ២០០៩ រហូតដល់ ខែ កក្កដា ឆ្នាំ ២០១២

រាជធានីភ្នំពេញ កម្ពុជា

សីហា ២០០៩

## I. សេចក្តីផ្តើម

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជា និងអង្គការសេវាសង្គមសុខភាពបុរស បានព្រមព្រៀងគ្នាពង្រឹងកិច្ចសហការ និងសម្របសម្រួលរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ដើម្បីពង្រឹងការលើកកំពស់សុខភាព និងការផ្តល់សេវាសុខភាព ជាពិសេសបង្ការការឆ្លងរាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងកាមរោគនៅប្រទេសកម្ពុជា។

អង្គការសេវាសង្គមសុខភាបបុរស គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលចុះបញ្ជីជាផ្លូវការ នៅក្រសួងមហាផ្ទៃ នាថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៤ ។

អង្គការសេវាសង្គមសុខភាពបុរសបានទទួលជំនួយហិរញ្ញវត្ថុពីអង្គការខាណា ( KHANA) អង្គការសុខភាពគ្រួសារអន្តរជាតិ ( FHI ) និងអង្គការភីអេសអាយ ( PSI ) ដើម្បីអនុវត្តការងារបង្ការ និងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងកាត់បន្ថយផលប៉ះពាល់ការប្រើប្រាស់គ្រឿងញៀន និងធ្វើទីផ្សារស្រោមអនាម័យទៅលើក្រុមប្រឈមមុខខ្ពស់ ( **បុរសស្រឡាញ់បុរស អ្នកប្រើប្រាស់គ្រឿងញៀន និង ស្ត្រីបំរើសេវាកំសាន្តសប្បាយ** ) ចំនួន០៩ ខេត្ត-រាជធានីដែលជាតំបន់គ្របដណ្តប់របស់អង្គការសេវាសង្គមសុខភាពបុរសដែលក្នុងនោះ រួមមាន **រាជធានីភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ កំពង់ធំ ព្រៃវែង កំពង់ឆ្នាំង កំពង់ស្ពឺ និង ប៉ៃលិន** ដោយគិតចាប់តាំងពីខែ **សីហា ឆ្នាំ ២០០៩ រហូតដល់ ខែ កក្កដា ឆ្នាំ ២០១២** ។

អង្គការសេវាសង្គមសុខភាពបុរស នឹងធានាថា គ្រប់សកម្មភាពនិងមូលនិធិដែលគាំទ្រដោយម្ចាស់ជំនួយរបស់ខ្លួនត្រូវបានដាក់បញ្ចូលក្នុងផែនការ និងធ្វើរបាយការណ៍ប្រចាំត្រីមាស, របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ-សុខាភិបាលខេត្ត-រាជធានី និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។

គោលបំណង សកម្មភាព និងទីតាំងដែលត្រូវធ្វើកិច្ចសហការរួមគ្នាចាប់តាំងពីខែ **សីហា ២០០៩ រហូតដល់ខែ កក្កដា ឆ្នាំ ២០១២** មាននឹងរៀបរាប់លំអិតនៅក្នុងចំនុចទី III ដូចខាងក្រោម ។

## II. គោលបំណង

- បង្ការការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។
- កាត់បន្ថយការចម្លងមេរោគអេដស៍/ជំងឺអេដស៍ និង កាត់ផលប៉ះពាល់ការប្រើប្រាស់គ្រឿងញៀន ។
- គាំទ្រ និងលើកទឹកចិត្តដល់ក្រុមបុរសស្រឡាញ់បុរសអោយប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ ។

## III. ទីតាំង និង តំបន់គោលដៅដែលត្រូវទទួលបានការគាំទ្រក្នុងកិច្ចសហប្រតិបត្តិការ រវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការសេវាសង្គមសុខភាពបុរស

អង្គការសេវាសង្គមសុខភាពបុរសប្តេជ្ញាចិត្តផ្តល់ការគាំទ្រ ទាំងផ្នែកគំរោងសកម្មភាព នៃការបង្ការការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ ( បុរសស្រឡាញ់បុរស អ្នកប្រើប្រាស់គ្រឿងញៀន និងស្ត្រីបំរើសេវាកំសាន្តសប្បាយ) ចំនួន ០៩ ខេត្ត-រាជធានី ក្នុងនោះរួមមាន **រាជធានីភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ កំពង់ធំ ពោធិ៍សាត់ ព្រៃវែង កំពង់ឆ្នាំង កំពង់ស្ពឺ និង ប៉ៃលិន** ។

**១-នៅក្នុងរាជធានីភ្នំពេញ** គ្របដណ្តប់១៨កន្លែងដែលប្រឈមមុខ ដូចជា ប្លុកធីលី នៅសង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ សាឡេញបារ នៅក្នុងសង្កាត់ផ្សារកណ្តាល ខ័ណ្ឌដូនពេញ កាលីសស៊ីសូណា អឹមសូម៉ាស្សា នៅក្នុងសង្កាត់ចតុមុខ ខ័ណ្ឌចំការមន អាមាមសូណា រ៉ូមែនតិចសូណា នៅក្នុងសង្កាត់បឹងកេងកង៣ ខណ្ឌ័-ចំការមន ហៃភគីស្ពាសូណា នៅក្នុងសង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ហត្ថាខ្មែរ ក្លឹបសិល្បះ នៅក្នុងសង្កាត់បឹងសាឡាង ខណ្ឌ័ទួលគោក ហាងការហ្វេទី១ ទី២ ទី៣ នៅក្នុងសង្កាត់ទំនប់ទឹក ខណ្ឌ័ចំការមន និងហាងការហ្វេទី១ ទី២ និង ទី៣ នៅពោចិនតុង សង្កាត់កាកាប ខណ្ឌ័ដង្កោ ។

**២-ខេត្តបាត់ដំបង** អង្គការសេវាសង្គមសុខភាពបុរសបានគ្របដណ្តប់៥ស្រុក ក្នុងនោះមានស្រុកបាត់ដំបងគ្របដណ្តប់ ១០ឃុំ ស្រុកបាណនគ្របដណ្តប់៣ឃុំ ស្រុកសង្កែរគ្រប់ដណ្តប់១៣ឃុំ ស្រុកឯកភ្នំគ្របដណ្តប់៨ឃុំ ស្រុកបាវិលគ្របដណ្តប់៣ឃុំ និង ស្រុកមោងឫស្សីគ្រដណ្តប់៣ឃុំ ។

**៣-ខេត្តកំពង់ឆ្នាំង** គ្របដណ្តប់៥ស្រុក ដូចជា ស្រុកកំពង់ឆ្នាំងគ្របដណ្តប់៤ឃុំ រលាប្អៀគ្របដណ្តប់៧ឃុំ ស្រុកកំពង់លែងគ្របដណ្តប់៤ឃុំ ស្រុកទឹកផុះគ្របដណ្តប់៣ឃុំ ស្រុកបរិបូគ្របដណ្តប់៤ឃុំ និងស្រុកកំពង់ត្រឡាចគ្របដណ្តប់៤ឃុំ ។

**៤-ខេត្តព្រៃវែង** គ្របដណ្តប់៤ស្រុក ដូចជា ស្រុកពាមរ៍គ្របដណ្តប់១១ឃុំ ស្រុកបាភ្នំគ្របដណ្តប់៣ឃុំ ស្រុកពាមជ័គ្របដណ្តប់៤ឃុំ និង ស្រុកព្រះស្តេចគ្របដណ្តប់៣ឃុំ ។

**៥-ខេត្តកំពង់ស្ពឺ** គ្របដណ្តប់ ៥ ស្រុក ដូចជា ស្រុកឧដ្តុងគ្របដណ្តប់២ឃុំ ស្រុកគងពិសីគ្របដណ្តប់៣ឃុំ ស្រុកច្បារមនគ្របដណ្តប់១១ឃុំ ស្រុកសំរោងទងគ្របដណ្តប់៤ឃុំ និង ស្រុកភ្នំស្រួចគ្របដណ្តប់៥ឃុំ។

**៦-ខេត្តពោធិសាត់** គ្របដណ្តប់៤ស្រុកដូចជា ស្រុកសំពៅមាស១៣ឃុំ ស្រុកក្រគរគ្របដណ្តប់៥ឃុំ ស្រុកបាកានគ្របដណ្តប់ ៥ឃុំ និង ស្រុកភ្នំក្រវ៉ាញ ៥ឃុំ ។

**៧-ខេត្តប៉ៃលិន** គ្របដណ្តប់២ស្រុក ដូចជា ស្រុកសាលាក្រៅគ្របដណ្តប់៤ឃុំ និង ស្រុកប៉ៃលិនគ្របដណ្តប់៣ឃុំ ។

**៨-ខេត្តបន្ទាយមានជ័យ** គ្របដណ្តប់២ស្រុក ដូចជា ស្រុកសេរីសោភណ្ឌគ្របដណ្តប់៤ឃុំ និងស្រុកមង្គលបុរីគ្របដណ្តប់៣ឃុំ ។

**៩- ខេត្តកំពង់ធំ** គ្របដណ្តប់៣ស្រុក ដូចជា ស្រុកស្ទឹងសែនគ្របដណ្តប់៤ឃុំ ស្រុកស្ទោងគ្របដណ្តប់ ២ឃុំ និង ស្រុកបារាណ៍គ្របដណ្តប់៤ឃុំ ។

## IV. ការទទួលខុសត្រូវរបស់ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ និង អង្គការសេវាសង្គមសុខភាពបុរស

**ភាគីទាំងពីរនឹងព្រមព្រៀងគ្នាតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :**

១-អង្គការសេវាសង្គមសុខភាពបុរស បញ្ជូនអ្នកសម្របសម្រួលសហគមន៍ និងមិត្តអប់រំមិត្តអោយចុះទៅអប់រំនៅតាមកន្លែង GUY BAR, GUY SAUNA, BEER GARDEN, CLUB, CAFE SHOP, MASSAGE CLUB និង នៅតាមសហគមន៍ទាំង១០ខេត្ត-រាជធានី ទៅដល់ក្រុមងាយប្រឈមមុខខ្ពស់នោះរួមមាន **រាជធានីភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ កំពង់ធំ ពោធិ៍សាត់ ព្រៃវែង កំពង់ឆ្នាំង កំពង់ស្ពឺ និង ប៉ៃលិន**។ ការអនុវត្តសកម្មភាពបង្ការទាំងអស់នេះ គឺស្របតាមផែនការយុទ្ធសាស្ត្រ និងនិយាមនៃបែបបទរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

២-អង្គការសេវាសង្គមសុខភាពបុរស នឹងគាំទ្រការបញ្ជូនក្រុមបុរសស្រឡាញ់បុរស០៥នាក់ និងស្ត្រីបំរើសេវាកំសាន្តសប្បាយ០៥នាក់ អ្នកចាក់គ្រឿងញៀន០២នាក់ អ្នកហិតគ្រឿងញៀន០២នាក់ ទៅទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ ក្នុង១សប្តាហ៍ម្តង និងគាំទ្រការបញ្ជូនក្រុមបុរសស្រឡាញ់បុរស០៥នាក់ និងស្ត្រីបំរើសេវាកំសាន្តសប្បាយ០៥នាក់ អ្នកចាក់គ្រឿងញៀន០២នាក់ អ្នកហិតគ្រឿងញៀន០២នាក់ ទៅទទួលសេវាពិនិត្យនិងព្យាបាលជំងឺកាមរោគ ក្នុងមួយថ្ងៃម្តង ។

៣-ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រុមបុរសស្រឡាញ់បុរស និងស្ត្រីបំរើសេវាកំសាន្តសប្បាយដែលអង្គការសេវាសង្គមសុខភាពបុរសបានបញ្ជូនមកពិនិត្យ និងព្យាបាលជំងឺកាមរោគនៅគ្លីនិកសុខភាពគ្រួសារ និងនៅមណ្ឌលសុខភាពនៅក្នុងខែនិមួយៗ ។

៤-អង្គការសេវាសង្គមសុខភាពបុរស បញ្ជូនបុគ្គលិកចំនួន០២នាក់ដែលជាបុរសស្រឡាញ់បុរស និង ស្ត្រីបំរើសេវាកំសាន្តសប្បាយ ដើម្បីជួយផ្តល់ការអប់រំ សម្របសំរួលការបញ្ជូនអោយទៅកាន់សេវាដែលត្រូវការ នៅគ្លិនិកសុខភាពគ្រួសារ និងនៅឯមណ្ឌលសុខភាព ទាំង ០៩ ខេត្ត-រាជធានី ជាពិសេស នៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

៥-មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ផ្តល់ជំនួយបច្ចេកទេសដល់ខេត្តទាំង១០ ព្រមទាំង រាជធានីភ្នំពេញដែលអង្គការសេវាសង្គមសុខភាពបុរស បាននិងកំពុងអនុវត្តសកម្មភាព ។

៦-បុគ្គលិកនៅគ្លីនិកសុខភាពគ្រួសារ និងបុគ្គលិកមណ្ឌលសុខភាពជាអ្នករៀបចំ និងរក្សាទុកវាល់ប័ណ្ណបញ្ជូនរបស់ក្រុមបុរសស្រឡាញ់បុរស និងស្ត្រីបំរើសេវាកំសាន្តសប្បាយក្នុងប្រអប់ដែលផ្តល់ជូនដោយអង្គការសេវាសង្គមសុខ-ភាពបុរស ដើម្បីងាយស្រួលក្នុងការប្រមូលសន្លឹកប័ណ្ណបញ្ជូនទាំងនោះត្រឡប់មកវិញដោយបុគ្គលិករបស់អង្គការនៅរៀងរាល់ចុងខែនិមួយៗ ។

៧-អង្គការសេវាសង្គមសុខភាពបុរស និងប្រើប្រាស់ប័ណ្ណបញ្ជូនជាលក្ខណៈស្តង់ដា រួមមាន បញ្ជីនិងប័ណ្ណបញ្ជូនសំរាប់ចុះលេខកូតអតិថិជននៅVCCT,បញ្ជីនិងប័ណ្ណបញ្ជូនសំរាប់ប្រើប្រាស់នៅសេវាពិនិត្យនិងព្យាបាលជំងឺកាមរោគ បញ្ជីនៅថែទាំ-ព្យាបាលជំងឺឱកាសនិយម (OI/ART) ហើយសន្លឹកប័ណ្ណបញ្ជូន និង បញ្ជីតាំងនេះបានបង្កើតដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ ក្នុងការបង្កលក្ខណៈងាយស្រួលដល់ក្រុមការងាររបស់អង្គការក្នុងការបញ្ជូនក្រុមគោលដៅទៅរកសេវាផ្សេងៗ ។

៨-តាមរយៈការប្រជុំប្រចាំខែ ប្រចាំត្រីមាសជាទៀងទាត់ រវាងបុគ្គលិកអង្គការសេវាសង្គមសុខភាពបុរស និងបុគ្គលិកគ្លីនិកសុខភាពគ្រួសារ បុគ្គលិកមណ្ឌលសុខភាព បុគ្គលិកកម្មវិធីអេដស៍ខេត្ត/ស្រុកប្រតិបត្តិ ដើម្បីផ្ទៀង-ផ្ទាត់របាយការណ៍ដែលបានបញ្ជូនដោយអ្នកសម្របសម្រួលមិត្តអប់រំមិត្ត និងអ្នកស្ម័គ្រចិត្តអប់រំសហគមន៍មកទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ សេវាពិនិត្យនិងព្យាបាលជំងឺកាមរោគនៅគ្លីនិកសុខភាពគ្រួសារដោយមានការផ្លាស់ប្តូរយោបល់ បទពិសោធន៍ពីគ្នាទៅវិញទៅមកក្នុងការកែលំអរលើកម្មវិធីអោយមានគុណភាព ប្រសិទ្ធភាព និង ប្រកបដោយភាពជោគជ័យឈានសម្រេចបានតាមគោលបំណងនិងទិសដៅរបស់គម្រោងដែលបានគ្រោងទុក ។

៩- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ ធានាថាសេវាពិនិត្យនិងព្យាបាលជំងឺកាមរោគ និង សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ នឹងត្រូវបានផ្តល់ជូនដល់ក្រុមចំណុចអោយមកប្រើប្រាស់សេវាទាំងនេះ ប្រកបដោយមិត្តភាពនិងគ្មានការរើសអើង ។

## V/ ប្រភពមូលនិធិ

ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល/មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ មន្ទីរសុខាភិបាលខេត្ត និងអង្គការសេវាសុខភាពបុរស បានទទួលជំនួយហិរញ្ញវត្ថុពីអង្គការខាណា ( KHANA) ចំនួនទឹកប្រាក់សរុប **US 115,096.00** អង្គការសុខភាពគ្រួសារអន្តរជាតិចំនួនទឹកប្រាក់សរុប **US 76,720.15** ( FHI ) និងអង្គការភី.អេស.អាយចំនួនទឹកប្រាក់សរុប **US27,549.20**(PSI) ដើម្បីបង្ការការរីករាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍ និង អ្នកប្រើប្រាស់គ្រឿងញៀនក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ 〈 **បុរសស្រឡាញ់បុរស អ្នកប្រើប្រាស់គ្រឿងញៀន និងស្ត្រីបំរើសេវាកំសាន្តសប្បាយ** 〉 ចំនួន ០៩ ខេត្ត-រាជធានី ក្រោមកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល មន្ទីរសុខាភិបាលខេត្ត-រាជធានីតាមកិច្ចប្រមព្រៀងនេះ ដែលត្រូវគិតចាប់ពីខែ សីហា ឆ្នាំ ២០០៩ រហូតដល់ ខែ កក្កដា ២០១២ ។

## VI/ បទប្បញ្ញត្តិទូទៅ

អង្គការសេវាសង្គមសុខភាពបុរសនឹងផ្តល់របាយការណ៍ប្រចាំត្រីមាសស្តីអំពីការបង្ការការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ និង ផលប៉ះពាល់ការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ទាំង០៩ខេត្ត-រាជធានីមកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ។ ក្នុងករណីមានការកែសំរួលខុសពីកិច្ចប្រមព្រៀងនេះត្រូវធ្វើការពិគ្រោះយោបល់ជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ។

អង្គការសេវាសង្គមសុខភាពបុរស និងផ្តល់របាយការណ៍ត្រីមាសជាប្រចាំពីក្រុមគោលដៅ (បុរសស្រឡាញ់បុរស អ្នកប្រើប្រាស់គ្រឿងញៀន និងស្ត្រីបំរើសេវាកំសាន្តសប្បាយ) ដែលបានបញ្ជូនរកសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ ពិនិត្យនិងព្យាបាលជំងឺកាមរោគទាំង ០៩ ខេត្ត-រាជធានីមកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ។

អង្គការសេវាសង្គមសុខភាពបុរស និងផ្តល់របាយការណ៍ត្រីមាសជាប្រចាំពីការចែកចាយស្រោមអនាម័យរបស់ទីផ្សារស្រោមអនាម័យ-សង្គមទាំង៧ខេត្ត-ក្រុង ( **រាជធានីភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ ព្រៃវែង ប៉ៃលិន កំពង់ធំ និង កំពង់ឆ្នាំង** ) មកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ ។

នីតិវិធីទូទៅ ការសម្របសម្រួល ការធ្វើផែនការ និងការគ្រប់គ្រងសកម្មភាព ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តរួមគ្នាដោយ NCHADS/MOH/PHD ក្នុងក្របខ័ណ្ឌការងាររបស់ NCHADS/MOH ស្តីពី “*ផែនការ*

*យុទ្ធសាស្ត្រដើម្បីថែទាំ និងបង្ការមេរោគអេដស៍ឆ្នាំ ២០០៨-២០១០* " និង អនុលោមតាមនីតិវិធីរបស់ NCHADS ស្តីការអនុវត្តគម្រោងសកម្មភាពដែលបានអនុម័តកាលពីខែ កុម្ភៈ ឆ្នាំ ២០០៦ ។

កិច្ចព្រមព្រៀងនេះមានសុពលភាពរយៈពេលពាឆ្នាំ ដោយគិតចាប់ពីខែ សីហា ឆ្នាំ ២០០៩ រហូតដល់ ខែ កក្កដាឆ្នាំ ២០១២ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ2010

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែក និងកាមរោគ**
**ប្រធាន**

**ឯកឧត្តម វេជ្ជ. មាន ឈីវុន**

**អង្គការសេវាសង្គមសុខភាពបុរស**
**នាយកប្រតិបត្តិ**

**លោក ផល សុផាត**

" **<u>ចម្លងជូន</u>** "

- មន្ទីរសុខាភិបាលរាជធានីភ្នំពេញ
- មន្ទីរសុខាភិបាលនិងការិយាល័យអេដស៍ខេត្តបាត់ដំបង
- មន្ទីរសុខាភិបាលនិងការិយាល័យអេដស៍ខេត្តបន្ទាយមានជ័យ
- មន្ទីរសុខាភិបាលនិងការិយាល័យអេដស៍ខេត្តពោធិ៍សាត់
- មន្ទីរសុខាភិបាលនិងការិយាល័យអេដស៍ខេត្តព្រៃវែង
- មន្ទីរសុខាភិបាលនិងការិយាល័យអេដស៍ខេត្តកំពង់ឆ្នាំង
- មន្ទីរសុខាភិបាលនិងការិយាល័យអេដស៍ខេត្តកំពង់ស្ពឺ
- មន្ទីរសុខាភិបាលនិងការិយាល័យអេដស៍ខេត្តប៉ៃលិន
- មន្ទីរសុខាភិបាលនិងការិយាល័យអេដស៍ខេត្តកំពង់ធំ